**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៧-១៥៨ ប្រ.ក

# ប្រកាស
# ស្ដីពី
# ការកែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសស្ដីពី ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្ដីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៥-០៩-២២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការដាក់ឱ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ
- យោងតាមការចាំបាច់របស់អគ្គនាយកដ្ឋានបច្ចេកទេស

## សម្រេច

**ប្រការ មួយ.~**

កែសម្រួលចំណុច ៥ ប្រការ ២ នៃប្រកាសលេខ ធ៥-០១០-១៨៣ ប្រ-ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្ដីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា មានដូចខាងក្រោម ៖

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២ថ្មី.~**

ចំណុច ៥ ថ្មី: មូលបត្រអាចជួញដូរបានមានឥណប្រតិទានគិតជាថ្ងៃលើមូលដ្ឋានសប្តាហ៍ ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ។ ឥណប្រតិទានអាចនឹងត្រូវបានកែតម្រូវដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃបញ្ចាទិញ ក្នុងករណីដែលឥណប្រតិទាននេះត្រូវចំថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋា-ភិបាលកម្ពុជា។

**ប្រកាស ពីរ.~**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួន ។

**ប្រការ បី.~**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៧

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល**:

-ដូចប្រការពីរ " **ដើម្បីអនុវត្ត**"

-កាលប្បវត្តិ

-ឯកសារ

**ចម្លងជូន**

-សមាជិកក្រុមប្រឹក្សាភិបាល

-ទីស្តីការគណៈរដ្ឋមន្ត្រី "**ដើម្បីជ្រាបជាព័ត៌មាន**"

-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"**ដើម្បីចុះផ្សាយក្នុងរាជកិច្ច**"